# អ្នកប្រាជ្ញ

តើមានអ្នកប្រាជ្ញ អាចយកបញ្ញាខ្លួនទៅបំរើជនពាលបានដែរឬទេ ?

ដកស្រង់ពីសុត្តន្តបិដក - ម្រឹគពោធិសត្វ ពោលថា : *ម្នាលនាងខរាទិយា យើងមិនអាចទូន្មានម្រឹគ មានក្រចក ៨ មានស្នែងវៀចគល់នឹងស្រួចចុងដ៏ក្រៃលែង ជាសត្វកន្លងនូវកាលដម្បូន្មាន ៧ នោះឡើយ។*

អ្នកប្រាជ្ញ ឬ បណ្ឌិត តែងតែមាន សីលធម៌ និង គុណធម៌ ហើយរមែងប្រកាន់ហេតុដែលមិនខុស វាខុសនឹងធាតុ នៃជនពាល ត្រិះរិះយកឯង រមែងប្រកាន់ហេតុខុស។ ហេតុខុស និងមិនខុសនេះហើយ ជាដែនជិតស្លុង រវាងអ្នកប្រាជ្ញ និង ជនពាល។ ដូច្នេះ វាគ្មានពន្លឺបញ្ញាអ្វីមួយរបស់អ្នកប្រាជ្ញ ដែលអាចជាដម្បូន្មាន សំរាប់ជនពាល យកទៅពិចារណាបាននោះឡើយ ព្រោះជនពាល រមែងលុះអំណាចអញ។

ជនណា ដែលតាំងខ្លួនជាអ្នកប្រាជ្ញ តែមានប្រាជ្ញាជាគ្រឿងបញ្ឆោត មានតម្លៃជាជនពាល ម្លោះហើយ ជនប្រភេទនេះ រមែងយកជនពាលជាមិត្ត។ អ្នកប្រាជ្ញបញ្ឆោតនេះ តែងធ្វើប្រយោជន៍អោយសាបសូន្យ ដូចស្វារក្សាសួន ព្រោះប្រាជ្ញា ជាគ្រឿងពិចារណាក្នុងធម៌បី សេចក្តីសង្វាត១ សេចក្តីក្លៀវក្លា១ បញ្ញា១ មិនមែនជាសេចក្តីបញ្ឆោតនោះទេ។ ដូច្នេះ អ្នកប្រាជ្ញ មិនអាចជាមិត្តនឹងជនពាលបានជាដាច់ខាត៕

**ឧប សៅ សង្ហា** **គំនិត** **១៣ មិថុនា ២០១៨**